FARMER NOTES

# ព្រឹត្តិប័ត្រព័ត៌មានកសិករ



ឆ្នាំទី ២ លេខ ១០ ខែមីនា ឆ្នាំ ២០០៣

ការចេញផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា
A Publication of the Cambodian Agricultural Research and Development Institute

# ការរៀបចំដី



ការភ្ជួរដោយត្រាក់ទ័រ + នង្គ័លថាស ៧

ការរៀបចំដី គឺជាការអនុវត្តន៍រួមគ្នានូវការភ្ជួរ-រាស់ដី ដើម្បីអោយវាស្ថិតក្នុងស្ថានភាពរូបសាស្ត្រល្អប្រសើរបំផុតសំរាប់ដំណុះគ្រាប់ពូជ និងការលូតលាស់របស់ដំណាំ។ ដើម្បីទទួលបានលក្ខខណ្ឌនេះ គេត្រូវតែភ្ជួររាស់ដីក្នុងជំរៅមួយដែលធ្វើអោយដំណាំអាចមានលទ្ធភាពចាក់ឬសបានល្អ ដើម្បីទ្រទ្រង់ដើម និងស្រូបយកសំណើមព្រមទាំងសារធាតុចិញ្ចឹមទាំងឡាយ សំរាប់សម្រេចបាននូវសក្តានុពលភាពនៃទិន្នផល។ គេត្រូវតែធ្វើការបំបែក និងច្របល់ដីអោយបានគ្រប់គ្រាន់ ដើម្បីបន្ថយ ឬបង្អន់នូវការប្រជែងពីស្មៅចង្រៃ។ ផ្ទៃដីខាងលើគួរតែធ្វើអោយបានរាបស្មើល្អ ដើម្បីធ្វើអោយការគ្រប់គ្រងទឹក និងការកំចាត់ស្មៅចង្រៃដែលទើបដុះថ្មីមានប្រសិទ្ធិភាពខ្ពស់ជាអតិបរមា។ ស្រែទាំងឡាយក៏ត្រូវការផងដែរនូវប្រព័ន្ធបង្ហូរ សំរាប់បង្ហូរចេញអោយបានរហ័សនូវទឹកដែលលើសពីសេចក្តីត្រូវការ។

**គោលបំណងនៃការរៀបចំដី:** អាស្រ័យទៅតាមប្រព័ន្ធដាំដុះ ការរៀបចំដីអាចសរុបទាំងការងារបំបែក និងច្របល់ដី គិតចាប់ពីការធ្វើវាក្នុងកំរិតអប្បបរមា (Zero-tillage) រហូតដល់ការវាយច្របល់ដីស្រែ (Puddle) ដោយបំផ្លាញរចនាសម្ព័ន្ធរបស់ដីទាំងស្រុង។ គោលបំណងផ្សេងៗនៃការរៀបចំដីគឺដើម្បី : **១**.បំបែកដុំដី **២**.យកចេញបង្កប់ ឬកាត់ចិញ្ច្រាំសំណល់នៃដំណាំ **៣**.បង្កើននូវលទ្ធភាពរបស់ដីសំរាប់ទាំងការទទួលសំណើម ទាំងការធ្វើអោយស្ងួត **៤**.កំចាត់ស្មៅចង្រៃ **៥**.ច្របល់ និងបង្កប់ជីជាតិ ឬជីទ្រាប់បាតទៅក្នុងដី **៦**.កំចាត់សត្វល្អិតចង្រៃ ពង កូនញាស់ និងសំបុករបស់វា **៧**.បន្ថយការហូរច្រោះដីដែលបង្កឡើងដោយខ្យល់ និងទឹក។

ដោយហេតុថា ដីគឺជាមជ្ឈដ្ឋានដែលមានលក្ខណៈសាំញ៉ាំខ្លាំង (វាមានទាំងសមាសភាគមានជីវិត ទាំងសមាសភាគនិចល ឬសមាសភាគផ្សំ) ធ្វើអោយការងារភ្ជួររាស់បែបណាក៏ដោយ ក៏អាចមានឥទ្ធិពលទៅលើដីដែរ ។ ប្រសិនបើដីត្រូវភ្ជួររាស់ដើម្បីកំចាត់ស្មៅចង្រៃ សំណើមរបស់វា នឹងត្រូវបាត់បង់, សំណល់នៃដំណាំដែលដាំពីមុននឹងត្រូវបង្កប់ ហើយទំហំដុំដី នឹងត្រូវបំបែកអោយតូច ។ ដូច្នេះ គឺជាការសំខាន់ដែលគេត្រូវកំណត់ អំពីគោលបំណងចំបងនៃកិច្ចប្រតិបត្តិនីមួយៗ ព្រមទាំងឥទ្ធិពល ឬបញ្ហាទាំងឡាយ ដែលនឹងអាចកើតមានពីកិច្ចប្រតិបត្តិនោះ ។

**ប្រព័ន្ធភ្ជួររាស់ដី:** ការងាររៀបចំដីអាចគិតជារួមថា ជាការភ្ជួររាស់ដីលើកទីមួយ (ភ្ជួរដាស់ដី) ឬលើកទីពីរ (ភ្ជួរប្រែ)។ ការភ្ជួររាស់ដីលើកទីមួយ គឺជាការងារធ្វើដីដំបូងបន្ទាប់ពីការប្រមូលផលនៃដំណាំដែលបានដាំពីមុន។ វាតែងត្រូវបានគេអនុវត្តឡើងជាធម្មតានៅក្រោយពេលច្រូតកាត់ភ្លាមៗ នៅដើមរដូវវស្សា គឺនៅពេលដែលដីមានសភាពសើមសមស្របអោយគេអាចភ្ជួរវាកើត ព្រមទាំងមានសភាពរឹងមាំគ្រប់គ្រាន់សំរាប់បង្កកុំអោយមានការផុងជាប់ជើងគោក្របី គោយន្ត ឬត្រាក់ទ័រ។ ប្រសិនបើមានថាមពលគ្រប់គ្រាន់ គេអាចភ្ជួរដីប្រភេទខ្លះបាន ទោះបីជានៅពេលដែលដីនោះមានសភាពស្ងួតខ្លាំងក៏ដោយ។

ឧបករណ៍ធ្វើដីដែលគេប្រើច្រើនជាងគេបំផុតជាមួយគោក្របីគឺ **នង្គ័លភ្ញៀង**។ សំរាប់ប្រភេទដីឥដ្ឋ ជារឿយៗគេតែងតែធ្វើអោយដីស្រែស្រូបទឹកបានឆ្អែតសិន ទើបការងារភ្ជួររាស់អាចប្រព្រឹត្តទៅបាន។ សំរាប់ប្រភេទដីដែលមានទំរង់ស្រាលជាងដីឥដ្ឋដូចជា ដីល្បាយខ្សាច់ ឬដីខ្សាច់ ការងារភ្ជួររាស់អាចប្រព្រឹត្តទៅបាននៅពេលដែលកំរិតសើមរបស់ដីស្ថិតក្នុងកំរិតទាប ឬមិនទាន់ឆ្អែតទឹកនៅឡើយ។ ជាមួយគោយន្ត គេអាចប្រើប្រាស់បានទាំង **នង្គ័លភ្ញៀង** និង **នង្គ័លថាស**។ គេនិយមប្រើនង្គ័លថាស ជាងនង្គ័លភ្ញៀង ដោយសារគេអាចចំណាយកំលាំងសំរាប់អូសទាញនង្គ័លថាសតិចជាងនង្គ័លភ្ញៀង ហើយនង្គ័លថាសអាចធន់ទ្រាំជាមួយឧបសគ្គផ្សេងៗ (ដង្គត់ឈើ ដុំថ្ម ... ) បានល្អជាងនង្គ័លភ្ញៀង។ ប្រសិនបើមានបញ្ហាអូសទាញមិនរួច (ទួងកង់) គេគួរយក**កង់ទ្រុង (កង់ដែក)**ទៅប្រើប្រាស់ជំនួសកង់កៅស៊ូធម្មតា។ ជាមួយត្រាក់ទ័រ គេចូលចិត្តប្រើ **នង្គ័លថាស៣ នង្គ័លថាស៧** និង **រនាស់ថាស** ជាងគេបំផុត។ យកល្អគេគួរប្រើប្រាស់នង្គ័លស្លាប ប៉ុន្តែគេពុំអាចមានលទ្ធភាពរកបានដើម្បីយកទៅប្រើប្រាស់អោយបានទូលំទូលាយឡើយ។ គេក៏ពុំសូវចូលចិត្តប្រើ នង្គ័លភ្ញៀង ជាមួយត្រាក់ទ័រផងដែរ។

**ការធ្វើអោយមានដីស្រទាប់រឹង:** សំរាប់ដីប្រភេទខ្លះ គេចង់បានស្រទាប់ដីរឹង ឬស្រទាប់ដីមិនជ្រាបទឹកនៅពីក្រោមស្រទាប់ដីភ្ជួររាស់ ដើម្បីទប់ទឹកមិនអោយជ្រាបទៅក្រោមហួសផុតស្រទាប់ចាក់ឫសរបស់ដំណាំស្រូវ។ គេអាចទទួលបានស្រទាប់ដីរឹងបែបនេះ ដោយប្រើប្រាស់ឧបករណ៍ណាដែលធ្វើអោយរលោងមុខលើរបស់ស្រទាប់នេះ ក្នុងពេលធ្វើការធម្មតា។ រ៉ូតាវ៉ាទ័រ (Rotavator) គឺជាឧបករណ៍ដ៏សមស្របជាងគេបំផុតសំរាប់ការងារនេះ។ ការទួងកង់ នៃត្រាក់ទ័រភ្ជាប់ដោយកង់ទ្រុង (កង់ដែក) អាចធ្វើអោយទទួលបានលទ្ធផលប្រហាក់ប្រហែលគ្នា។ ដូចគ្នានេះដែរ នង្គ័លថាស រនាស់ថាស ឬ រនាស់ដែលមានស្ពិតថាសបញ្ច្រាស់បណ្តោយគ្នា (ឬពីមុខពីក្រោយគ្នា) ធ្វើការនៅលើដីសើម ឬមានទឹកអាចផ្តល់នូវលទ្ធផលប្រហាក់ប្រហែលគ្នា។

តាមរយៈការសិក្សាកន្លងមក របស់កម្មវិធីវិស្វកម្មកសិកម្មនៃកម្មវិធីកម្ពុជា-អ៊ីរី-អូស្ត្រាលី និងក្រោយមកវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា អាចកំណត់បានថា :

- ការភ្ជួររាស់ដី ១ ហិកតា ជាទូទៅត្រូវចំណាយពេលជាមធ្យម :
  - ពី ៥ ទៅ ៨ នឹម-ថ្ងៃ ដោយប្រើប្រាស់ប្រាស់សត្វពាហនៈ (៥ ម៉ោង ក្នុង ១ ថ្ងៃ )
  - ពី ៣ ទៅ ៥ ម៉ោងដោយប្រើប្រាស់គោយន្ត ជាមួយពលកម្មមនុស្ស ២នាក់
  - ពី ១ ទៅ ២ ម៉ោង ដោយប្រើប្រាស់ត្រាក់ទ័រ ១ គ្រឿង ភ្ជាប់ជាមួយនង្គ័លថាស ៦ ឬ ៧។
- ជំរៅភ្ជួរ-រាស់ ប្រែប្រួលទៅតាមប្រភេទដី និងអាស្រ័យទៅនឹងកំរាស់នៃដីស្រទាប់លើ (Top Soil)។ តារាងខាងក្រោមបង្ហាញពីជំរៅភ្ជួរ-រាស់ អាស្រ័យទៅតាមប្រភេទដីនិមួយៗ :

| **ប្រភេទដី** | **ព្រៃខ្មែរ** | **ប្រទះឡាង** | **បាកាន** | **ទួលសំរោង** | **គោកត្រប់** | **កំពង់សៀម** | **ក្បាលពោធិ៍** |
|---|---|---|---|---|---|---|---|
| **ជំរៅភ្ជួរ-រាស់, cm** | 8 - 10 | 8 - 12 | 15 - 20 | 20 - 25 | 20 - 25 | 10 - 20 | 15 - 25 |

ប្រសិនបើការភ្ជួររាស់ដីត្រូវបានធ្វើឡើងដោយត្រឹមត្រូវ :

- អាចរក្សាភាពរាបស្មើរបស់ដីស្រែបានយូរ ហើយការពង្រាបជាថ្មីអាចនឹងត្រូវអនុវត្តនៅ ៨ ទៅ ១០ ឆ្នាំក្រោយ
- ងាយស្រួលក្នុងការគ្រប់គ្រងទឹក និងស្មៅចង្រៃ
- មានលទ្ធភាពផ្លាស់ប្តូរពីការដាំដុះដោយវិធីដកស្ទូង មកវិធីព្រោះ ឬ ដាំគ្រាប់ផ្ទាល់ដោយម៉ាស៊ីន ដែលធ្វើអោយថយចុះពលកម្មពីប្រមាណ ៣៥ មកត្រឹម ១ ទៅ ២ នាក់-ថ្ងៃ ក្នុងស្រែ ១ ហិកតា។ល។












សំរាប់ព័ត៌មានបន្ថែមសូមធ្វើការទាក់ទង ការិយាល័យវិស្វកម្មកសិកម្ម ឬ មជ្ឈមណ្ឌលបណ្តុះបណ្តាល និងព័ត៌មាន ឬ ការិយាល័យផែនការ សហប្រតិបត្តិការ និងពាណិជ្ជកម្ម នៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា នៅតាមបណ្តោយផ្លូវជាតិលេខ ៣ សង្កាត់ប្រទះឡាង ខ័ណ្ឌដង្កោ រាជធានីភ្នំពេញ ឬ តាមប្រអប់សំបុត្រលេខ ០១ ភ្នំពេញ.

ទូរស័ព្ទលេខ: (៨៥៥-២៣ )៦៣១៩ ៦៩៣- ៤ ទូរអក្សរ: cardi@cardi.org.kh វែបសាយ: www.cardi.org.kh

Sbunna@cardi.org.kh TRIN@cardi.org.kh HUNYADANA@cardi.org.kh